ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ក្រសួងព័ត៌មាន
លេខ......០៥៥..........ព.មសសរ

ថ្ងៃច័ន្ទ ១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣

# សេចក្ដីសម្រេច

## ស្ដីពីការបង្កើតគណៈកម្មការរៀបចំទទួលគណៈប្រតិភូអ្នកសារព័ត៌មានអាស៊ាន មកចូលរួមកម្មវិធីប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ នៅកម្ពុជា ២០២៣

----------------

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ២០២ នស.រកម ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកម.០១៩៦.១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងព័ត៌មាន ។

## សម្រេច

**ប្រការ ១** : បង្កើតគណៈកម្មការរៀបចំទទួល និងបដិសណ្ឋារកិច្ចគណៈប្រតិភូអ្នកសារព័ត៌មានអាស៊ាន មកចូលរួមកម្មវិធីប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ នៅកម្ពុជា ដែលគ្រោងនឹងមកបំពេញទស្សនកិច្ច ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ដែលសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម លី វ៉ាន់ហុង | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម ហាស់ សំអាត | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម ផុស សុវណ្ណ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកព័ត៌មាន និងសោតទស្សន៍ | អនុប្រធាន |
| ៤- ឯកឧត្តម ជ្រឹម ឆេងលីម | ទីប្រឹក្សា-អគ្គនាយករង រដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក ឋោ សេដ្ឋាឧត្តម | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

| | | |
|---|---|---|
| ៦- ឯកឧត្តម លន់ ហួរ | ទីប្រឹក្សា-ប្រធាននាយកដ្ឋានផែនការ គណនេយ្យ | សមាជិក |
| ៧- លោក ចន្ទ័ វិឡ្សន៍ | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- លោក គឹង ពុធតារា | អនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ | សមាជិក |
| ៩- លោក នង ស៊ីណា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០- លោក មុត មីរ៉ាបូ | អនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ | សមាជិក |
| ១១- លោក ស្លេះ អាល់ហ៊ីន | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២- លោក សន បូរ៉ា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៣- លោក ហាស់ សុចិត្រា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៤- លោក សាន់ ណារិន | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥- លោក មាស បុរីវិឡ្សនៈ | អនុប្រធានការិយាល័យអាស៊ាន | សមាជិក |
| ១៦- លោក មនោ កែវសុចេស្តា | មន្ត្រីការិយាល័យអាស៊ាន | សមាជិក |
| ១៧- លោក នូ ទិត្យា | មន្ត្រីការិយាល័យសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- លោក ហ៊ី សុភា | មន្ត្រីការិយាល័យសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច ៖

- លើកគម្រោងចំណាយសម្រាប់ពិធីជប់លៀង វត្តអនុស្សាវរីយ៍ និងពិធីបដិសណ្ឋារកិច្ចផ្សេងៗ
- រៀបចំឯកសារនិងបែបបទនានាសម្រាប់អ្នកសារព័ត៌មានអាស៊ានមកចូលរួមកម្មវិធីប្រកួតកីឡាស៊ីហ្គេម លើកទី ៣២ នៅកម្ពុជា
- រៀបចំរថយន្ត អាហារ ពិធីជប់លៀង វត្ថុអនុស្សាវរីយ៍ និងពិធីបដិសណ្ឋារកិច្ចផ្សេងៗ
- រៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ តាមកម្មវិធីដែលបានកំណត់
- អនុវត្តកិច្ចការផ្សេងៗទៀតតាមការចាំបាច់ និងតាមការណែនាំរបស់ថ្នាក់ដឹកនាំ

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ និងសាមីខ្លួនត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

**ខៀវ កាញារីទ្ធ**

កន្លែងទទួល :
-ថ្នាក់ដឹកនាំក្រសួង «ដើម្បីជូនជ្រាប»
-ដូចប្រការ ១-៣
-សាមីជន
«ដើម្បីអនុវត្តន៍»
-ឯកសារ, កាលប្បវត្តិ